# សូមបន្តមានសុខភាពល្អសម្រាប់គ្រួសាររបស់អ្នក។ គ្រួសាររបស់អ្នកត្រូវការអ្នក។

ព័ត៌មានអំពីជំងឺមហារីក និងការគាំទ្រ
សូមទូរសព្ទមកលេខ **13 11 20**
ឬចូលមើលគេហទំព័រ
**cancervic.org.au**

## សម្រាប់ព័ត៌មានបន្ថែម

ប្រសិនបើអ្នកចង់និយាយជាមួយនរណាម្នាក់ ជាភាសារបស់អ្នក សូមទូរសព្ទមកលេខ **13 14 50** ហើយស្នើសុំ ក្រុមប្រឹក្សាជំងឺមហារីក រដ្ឋវិចថូរៀ **(Cancer Council Victoria)**។

## ការណាត់ជួបរបស់អ្នក

- [ ] **និយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីការឆ្លុះមើលពោះវៀន**
  ដើម្បីរកមើលថានៅពេលណាអ្នកនឹងទទួលបានកញ្ចប់ធ្វើតេស្តឆ្លុះមើលនៅផ្ទះ តាមលេខ **1800 627 701**

  កាលបរិច្ឆេទ៖ ____________________

  ទីតាំង៖ ____________________

- [ ] **កក់ទុក ការថតពិនិត្យដោះរបស់អ្នក**
  ចូលមើលគេហទំព័រ breastscreen.org.au ឬទូរសព្ទមកលេខ **13 20 50**

  កាលបរិច្ឆេទ៖ ____________________

  ទីតាំង៖ ____________________

- [ ] **កក់ទុកការធ្វើតេស្តឆ្លុះមើលមាត់ស្បូនរបស់អ្នក**
  ស្វែងរកអ្នកផ្ដល់សេវាកម្មនៅលើគេហទំព័រ cancervic.org.au/CervicalDirectory ឬស្វែងយល់បន្ថែមអំពីការឆ្លុះមើលមាត់ស្បូន សូមទូរសព្ទមក **Cancer Council** តាមលេខ **13 11 20**

  កាលបរិច្ឆេទ៖ ____________________

  ទីតាំង៖ ____________________



AP1707-4/2021

Cancer Council

# ត្រូវឆ្លុះមើល។ រស់នៅបានកាន់តែយូរ។

**ហានិភ័យជំងឺមហារីករបស់អ្នកកើនឡើងចាប់ពីអាយុ 50 ឆ្នាំ**

ការឆ្លុះមើលជួយឱ្យអ្នករកឃើញជំងឺមហារីកបានមុនពេល ឬថែមទាំងទប់ស្កាត់វាបានទៀតផង។

> ជំងឺមហារីកពោះវៀន
> ជំងឺមហារីកដោះ
> ជំងឺមហារីកមាត់ស្បូន



## ការឆ្លុះមើលពោះវៀន

**ប្រសិនបើអ្នកមានអាយុ 50-74 ឆ្នាំ** អ្នកគួរតែឆ្លុះមើលមើលជំងឺមហារីកពោះវៀន រៀងរាល់ពីរឆ្នាំម្តង ដោយប្រើការធ្វើតេស្តឆ្លុះមើលនៅផ្ទះដោយឥតគិតថ្លៃ។

ការធ្វើតេស្តនេះរកមើលឈាមនៅក្នុងចលនាពោះវៀន(លាមក) ដែលយើងប្រហែលជាមិនអាចមើលឃើញ ហើយអាចជាសញ្ញានៃជំងឺមហារីកពោះវៀន។ អ្នកអាចធ្វើតេស្ត នៅផ្ទះបាន។

ការធ្វើតេស្តនេះគឺសម្រាប់បុរស និងស្ត្រីដែលមិនមានសញ្ញា ឬរោគសញ្ញា ហើយពុំមានប្រវត្តិគ្រួសារមានជំងឺមហារីកពោះវៀន។

កញ្ចប់ធ្វើតេស្តឆ្លុះមើលនៅផ្ទះដោយឥតគិតថ្លៃ ត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅដល់មនុស្សដែលមានអាយុ 50-74 ឆ្នាំ រៀងរាល់ពីរឆ្នាំម្តង ដែលជាផ្នែកនៃ កម្មវិធីឆ្លុះមើលជំងឺមហារីកពោះវៀនថ្នាក់ជាតិ (National Bowel Cancer Screening Program)។

**ឥតគិតថ្លៃតាមរយៈ**: **កម្មវិធីថ្នាក់ជាតិ។**




**មានជំងឺមហារីកពោះវៀនជាង 9 ក្នុងចំណោមជំងឺមហារីកពោះវៀន 10 អាចព្យាបាលបានដោយជោគជ័យ ប្រសិនបើបានរកឃើញមុនពេល។**

## ការថតពិនិត្យដោះ

**ប្រសិនបើអ្នកមានអាយុ 50-74 ឆ្នាំ** អ្នកគួរតែមានការថតពិនិត្យដោះរៀងរាល់ពីរឆ្នាំម្តង។

ការថតពិនិត្យដោះ (កាំរស្មីអ៊ិច) រកមើលជំងឺមហារីកក្នុងដោះរបស់អ្នក។

ការថតពិនិត្យដោះត្រូវបានធ្វើឡើងជាលក្ខណៈឯកជនជាមួយអ្នកជំនាញថតកាំរស្មីអ៊ិចស្ត្រីម្នាក់ ហើយចំណាយពេលតែពីរបីនាទីប៉ុណ្ណោះ។ អ្នកអាចយកមិត្តភក្តិ ឬសមាជិកគ្រួសារមកជាមួយ ប្រសិនបើវាធ្វើឱ្យអ្នកមានអារម្មណ៍កាន់តែសុខស្រួល។

ការថតពិនិត្យដោះគឺសម្រាប់ស្ត្រីដែលមិនមានសញ្ញា ឬរោគសញ្ញាជំងឺមហារីកដោះ ហើយពុំមានប្រវត្តិគ្រួសារមានជំងឺមហារីកដោះ ឬដៃស្បូន។

**ឥតគិតថ្លៃតាមរយៈ**: BreastScreen Victoria។



**ការរកឃើញជំងឺមហារីកដោះបានកាន់តែមុនពេល នោះនឹងមានឱកាសកាន់តែប្រសើរក្នុងការព្យាបាលបានប្រកបដោយជោគជ័យ។**

## ការឆ្លុះមើលមាត់ស្បូន

**ប្រសិនបើអ្នកមានអាយុ 25-74 ឆ្នាំ** ហើយអ្នកធ្លាប់មានសកម្មភាពខាងផ្លូវភេទ អ្នកគួរតែមានការធ្វើតេស្តឆ្លុះមើលមាត់ស្បូន រៀងរាល់ប្រាំឆ្នាំម្តង។

អ្នកត្រូវការធ្វើតេស្តឆ្លុះមើលមាត់ស្បូន សូម្បីតែបន្ទាប់ពីទទួលបានវ៉ាក់សាំង HPV ឬអស់រដូវក៏ដោយ។

ការធ្វើតេស្តឆ្លុះមើលមាត់ស្បូន រកមើលមេរោគ HPV ដែលអាចវិវត្តទៅជាជំងឺមហារីកមាត់ស្បូនទៅតាមពេលវេលា ប្រសិនបើមិនបានព្យាបាល។

វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក អាចផ្តល់ការធ្វើតេស្តឆ្លុះមើលមាត់ស្បូនបាន។

ការធ្វើតេស្តឆ្លុះមើលមាត់ស្បូន គឺសម្រាប់ស្ត្រីដែលមិនមានសញ្ញា ឬរោគសញ្ញាជំងឺមហារីកមាត់ស្បូន។

**គ្លីនិកខ្លះ ផ្តល់ការឆ្លុះមើលមាត់ស្បូនដោយឥតគិតថ្លៃ។ សូមឆែកមើលថ្លៃចំណាយ នៅពេលធ្វើការណាត់ជួបរបស់អ្នក។**



**ការឆ្លុះមើលមាត់ស្បូនអាចជួយសង្គ្រោះជីវិតអ្នក។**